# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅកំពង់សោម
# ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៩
# គ្រួសារដ៏សុខសាន្ត

**អត្ថបទទី១៖ អេសាយ ៤០,១-៥.៩-១១**

ព្រះអង្គនឹងថែរក្សាប្រជារាស្ត្ររបស់ព្រះអង្គ ដូចគង្វាលថែរក្សាហ្វូងចៀមរបស់ខ្លួន។ ព្រះអង្គលើកព្រះហស្តឡើងប្រមូលកូនចៀម ព្រះអង្គបីកូនតូចៗជាប់នឹងព្រះឱរា ហើយព្រះអង្គថែទាំមេចៀម ដែលកំពុងបំបៅកូនផងដែរ។ អស ៤០,១១

**អត្ថបទទី២៖ ទីតុស ២,១១-១៤**

ព្រះអង្គបានបូជាព្រះជន្មរបស់ព្រះអង្គផ្ទាល់សម្រាប់យើង ដើម្បីលោះយើងឲ្យរួចផុតពីអំពើទុច្ចរិតគ្រប់យ៉ាង និងជម្រះប្រជារាស្ត្រមួយទុកសម្រាប់ព្រះអង្គផ្ទាល់ ជាប្រជារាស្ត្រដែលខ្នះខ្នែងប្រព្រឹត្តអំពើល្អ។ ទត ២,១៤

**ដំណឹងល្អ៖ លូកា ៣,១៥-១៦.២១-២២**

ហើយព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះមក មានរូបរាងដូចសត្វព្រាប សណ្ឋិតលើព្រះអង្គ។ មានឮព្រះសូរសៀងពីលើមេឃមកថា៖ «ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់»។ លក ៣,២២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ដែលយើងគោរពពិធីជ្រមុជទឹករបស់ព្រះយេស៊ូ ក្នុងអត្ថបទទីពីរ "**ព្រះជាម្ចាស់បានសម្តែងព្រះហឫទ័យប្រោសប្រណីមកដើម្បីសង្គ្រោះមនុស្សទាំងអស់**"។ នៅក្នុងយប់បុណ្យព្រះយេស៊ូប្រសូត យើងបានឃើញយ៉ាងជាក់ស្តែងអំពីសេចក្តីស្រឡាញ់ អំពីមេត្តាករុណា អំពីការយកចិត្តទុកដាក់របស់ព្រះជាម្ចាស់សម្រាប់មនុស្សលោក។ មានព្រះបន្ទូលមួយថា "**ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកយ៉ាងខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គបានប្រទានព្រះយេស៊ូដែលជាបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ យាងមកក្នុងពិភពលោកនេះដើម្បីណែនាំឲ្យមនុស្សលោកទាំងអស់ទទួលការសង្គ្រោះ**"។ ពីថ្ងៃបុណ្យព្រះយេស៊ូប្រសូតរហូតដល់ថ្ងៃនេះ ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត យើងបានឃើញព្រះយេស៊ូចាប់កំណើតជាមនុស្ស ព្រះយេស៊ូបង្ហាញឋានៈជាព្រះជាម្ចាស់ ព្រះយេស៊ូរស់នៅក្នុងក្រុមគ្រួសារដ៏វិសុទ្ធ។ ថ្ងៃនេះព្រះយេស៊ូធ្វើពិធីជ្រមុជទឹក ជាលើកទីពីរដែលព្រះយេស៊ូបានបង្ហាញឋានៈជាព្រះជាម្ចាស់ ដោយសារយើងបានស្តាប់ថា "**ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់**"។

ពីថ្ងៃដែលព្រះយេស៊ូប្រសូត យើងដឹងថាព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ និងបានណែនាំឲ្យមនុស្សលោកទទួលការសង្គ្រោះ។ ការសង្គ្រោះ គឺទទួលជីវិតថ្មី ការសង្គ្រោះ

មិនមែនជាអ្វីដែលយើងនិយាយនៅថ្ងៃទទួលមរណភាព ការសង្គ្រោះចាប់ផ្តើមពីពេលនេះតទៅ។ ការសង្គ្រោះចាប់ផ្តើម នៅពេលព្រះយេស៊ូបានប្រសូតនៅក្នុងក្រុមគ្រួសារដ៏វិសុទ្ធ ព្រះជាម្ចាស់បានថែរក្សាឲ្យក្រុមគ្រួសារទៅជាទ្រព្យសម្បត្តិយ៉ាងពិសេស ជីវិតល្ងូតលាស់ផុសនៅក្នុងក្រុមគ្រួសារមានឪពុក ម្តាយ និងកូន។ ព្រះយេស៊ូបានចាប់កំណើតនៅក្នុងក្រុមគ្រួសារមួយធម្មតា ជាមួយព្រះនាងម៉ារីនិងលោកយ៉ូសែប ដើម្បីបង្កើតគ្រួសារមួយដ៏សុខសាន្ត។ គ្រួសារមួយដ៏សុខសាន្ត ដោយសារឪពុកនិងម្តាយចេះស្រឡាញ់គ្នា ដោយសារឪពុកម្តាយចេះថែរក្សាកូន ដោយសារឪពុកម្តាយនិងកូនរស់នៅក្នុងសេចក្តីសុខរួមជាមួយអ្នកជិតខាង។

គ្រួសារមួយដ៏សុខសាន្ត ជាគ្រួសារមួយដែលមានកូនចេះថែរក្សាកូននៅក្នុងសេចក្តីស្រឡាញ់ នៅក្នុងការយកចិត្តទុកដាក់ នៅក្នុងការអប់រំ ព្រះនាងម៉ារីបានអប់រំព្រះយេស៊ូ ដល់ពេលវេលាណែនាំឲ្យកូនទៅវិសាលវិហារនៅទីក្រុងយេរ៉ូសាឡឹម ដើម្បីគោរពពិធីបុណ្យនានាតាមប្រពៃណី។ គ្រួសារមួយដ៏សុខសាន្ត ជាគ្រួសារមួយដែលអប់រំកូនទាំងចំណេះដឹងទាំងជីវិតប្រចាំថ្ងៃ ទាំងរស់នៅក្នុងសីលធម៌ ទាំងគោរពសាសនានិងប្រពៃណី។ គ្រួសារដ៏សុខសាន្ត ជាគ្រួសារមួយដែលរស់នៅក្នុងសង្គមបច្ចុប្បន្ន និងចេះបង្កើតទំនាក់ទំនងជាមួយគ្រួសារដទៃ។

ព្រះយេស៊ូបានចាប់កំណើតនៅក្នុងក្រុមគ្រួសារមួយ គ្រួសារនេះបានណែនាំឲ្យដឹងថា បើយើងចង់ទទួលជីវិតថ្មី បើយើងចង់បង្កើតពិភពថ្មី។ យើងអាចធ្វើបានលុះត្រាតែយើងចេះបង្កើតគ្រួសារដែលចេះស្រឡាញ់គ្នាទៅវិញទៅមក ចេះគោរពគ្នាទៅវិញទៅមក ចេះរស់នៅក្នុងសង្គមយ៉ាងសមរម្យដោយបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗ ដោយមានចិត្តអាណិតមេត្តាជានិច្ច។ នៅក្នុងអត្ថបទទីមួយ "**ព្រះអង្គនឹងថែរក្សាប្រជារាស្ត្ររបស់ព្រះអង្គដូចគង្វាលថែរក្សាហ្វូងចៀមរបស់ខ្លួន ព្រះអង្គលើកព្រះហស្តឡើងប្រមូលហ្វូងចៀម ព្រះអង្គបីកូនតូចៗជាប់នឹងព្រះឱរា ហើយព្រះអង្គថែទាំមេចៀមដែលកំពុងបំបៅកូនផងដែរ**" នេះជារបៀបរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ជាគ្រូគង្វាលដ៏សប្បុរស ពេលយើងអាននេះហើយយើងមានអារម្មណ៍ថាព្រះជាម្ចាស់បីដូចជាឪពុកម្តាយ ដូចម្តាយដែលបីកូនតូចៗជាប់នឹងឱរា ដូចឪពុកដែលថែទាំមេចៀមដែលកំពុងបំបៅកូន។ ព្រះជាម្ចាស់ជាឪពុកម្តាយរបស់យើង ព្រះជាម្ចាស់ថែទាំងយើងដូចម្តាយដែលណែនាំឲ្យយើងមានភាពកក់ក្តៅ ណែនាំឲ្យយើងមានការលើកទឹកចិត្ត ណែនាំឲ្យយើងពោរពេញដោយសេចក្តីស្រឡាញ់នៅក្នុងរបៀបដែលម្តាយស្រឡាញ់ថែរក្សាកូន ដូចឪពុកដែលអប់រំណែនាំ បំភ្លឺផ្លូវនៃជីវិត ដើម្បីឲ្យគ្រួសារអាចមានគោលដៅយ៉ាងច្បាស់ ធ្វើដំណើរនៅក្នុងផ្លូវត្រឹមត្រូវ នៅក្នុងសេចក្តីពិត នៅក្នុងភក្តីភាព។

យើងធ្វើដូចម្តេច ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាក្រុមគ្រួសារមួយយ៉ាងធំដែលចេះស្រឡាញ់ ដែលចេះថែរក្សា ដែលចេះយកចិត្តទុកដាក់ ដែលចេះណែនាំឲ្យកូនតូចៗមានសេ

ចក្តីសង្ឃឹមនៅក្នុងជីវិត។ ពេលយើងទៅជាមួយសាសនាទាំងអស់នៅមន្ទីរពេទ្យ ពីបន្ទប់មួយទៅបន្ទប់មួយដូចជាយើងបានបង្កើតបរិយាកាសគ្រួសារមួយយ៉ាងធំ។ យើងបានជួបអ្នកជំងឺធ្ងន់ អ្នកជំងឺល្មម ម្តាយទើបនឹងឆ្លងទន្លេ... ជាមួយព្រះសង្ឃដែលប្រោសទឹក ជាមួយខ្ញុំនិងលោកឪពុកសុនដែលអធិដ្ឋាន ជាមួយអ៊ីមាំដែលសួរសុខទុក្ខ។ ព្រះសហគមន៍កាតូលិក បានទទួលតួនាទីមួយយ៉ាងធំ គឺណែនាំឲ្យមនុស្សចេះរួបរួមគ្នានៅក្នុងគ្រួសារមួយដែលចេះលើកទឹកចិត្តគ្នា ចេះបង្កើតបរិយាកាសមួយដែលបង្ហាញថាមនុស្សទាំងអស់មានតម្លៃ។ នេះជារបៀបដែលយើងបង្កើតជីវិតថ្មីដើម្បីទទួលការសង្គ្រោះ ធ្វើយ៉ាងណាឲ្យយើងធ្វើជាពន្លឺហ្នឹង។

យើងធ្វើយ៉ាងណា ឲ្យព្រះសហគមន៍កាតូលិកនៅទីក្រុងព្រះសីហនុ ទៅជាកន្លែងមួយពិសេសដើម្បីបង្ហាញពន្លឺរបស់ព្រះគ្រីស្ត។ ភូមិកំណើតរបស់ព្រះយេស៊ូតូចណាស់ ប៉ុន្តែមានហោរាចារ្យដែលបានទៅដល់ភូមិបេថ្លេហឹមដើម្បីគោរពព្រះឱរសយេស៊ូ ដោយដើរតាមផ្កាយដែលបាននាំផ្លូវគេ។ ដូច្នេះកន្លែងយើង ទោះបីមានអាគារខ្ពស់ជុំវិញយើង ត្រូវដឹងថាមានផ្កាយមួយដែលភ្លឺនៅលើផ្ទៃមេឃ និងណែនាំឲ្យប្រជាជនស្គាល់កន្លែងយើង។ ជាកន្លែងដែលគេរកឃើញសេចក្តីពិត ជាពិសេសនៅក្នុងទីក្រុងព្រះសីហនុយើងសព្វថ្ងៃ។ យើងធ្វើដូចម្តេចដើម្បីឲ្យនៅទីនេះ ធ្វើជាកន្លែងពិសេសដើម្បីការពារថែរក្សាព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ដែលចាប់កំណើតជាមនុស្ស ដើម្បីធ្វើជាកន្លែងមួយដែលយើងសម្តែងធម៌មេត្តាករុណាជាមួយអ្នកជំងឺជាមួយជនពិការ ជាមួយកូនមត្តេយ្យ ជាមួយចាស់ជរា ជាមួយបងប្អូនទាំងអស់ដែលឥតមានផ្លូវនៅក្នុងជីវិតឲ្យរកឃើញសេចក្តីសង្ឃឹម។

ម្សិលមិញ ពេលកូនពិការជាមួយម្តាយគេមកពីភូមិសុខសាន្ត បានមកលេងទឹកសមុទ្រនៅកំពង់សោម គេបានលេងយ៉ាងសប្បាយភ្លេចទុក្ខលំបាកនៅក្នុងជីវិតរបស់គេ។ យើងជាមនុស្សដែលជាតំណាងរបស់ព្រះជាម្ចាស់ដែលព្រះជាម្ចាស់ស្រឡាញ់ ថែរក្សា លើកទឹកចិត្ត ដោយដឹងថាធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ គង់នៅជាមួយយើងដែលជាគ្រីស្តបរិស័ទ គង់នៅក្នុងបេសកកម្មដែលយើងបន្តពីព្រះជាម្ចាស់។ យើងត្រូវចាំថាទោះបីយើងនៅជាន់ខ្ពស់បំផុត ឬទាបផ្ទាល់ដី យើងនៅជាប់ជាមួយព្រះជាម្ចាស់បានលុះត្រាតែយើងកែប្រែចិត្តគំនិត យើងបើកចិត្តគំនិតរបស់យើង ដើម្បីចេះមើលទុក្ខលំបាករបស់បងប្អូនឯទៀតៗ។ យើងទាំងអស់ធ្វើយ៉ាងណាឲ្យយើងទៅជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ដែលបង្ហាញធម៌មេត្តាករុណាទៅគ្រប់ទីកន្លែងពន្លឺរបស់ព្រះគ្រីស្តនឹងបំភ្លឺមនុស្សយ៉ាងច្រើន ដើម្បីឲ្យគេភ្ញាក់ស្មារតីដោយបង្កើតក្រុមគ្រួសារមួយគឺគ្រួសាររបស់ព្រះគ្រីស្ត គ្រួសារដែលចេះទទួលស្វាគមន៍ជានិច្ចនៅក្នុងសេចក្តីស្រឡាញ់ពិតមែន។ យើងដឹងថា ហោរាចារ្យថ្ងៃណាមួយមកដល់ទីនេះ ដើម្បីមើលឃើញសេចក្តីពិត គឺព្រះយេស៊ូដែលគង់នៅទីនេះ។ អាម៉ែន៕